# Living the Lotus 7

## Buddhism in Everyday Life

2026
VOL. 250














## RKINA Holds National Leaders Training in Los Angeles, June 5–7, with Dr. Dominick Scarangello as Guest Lecturer

**Living the Lotus**
**Vol. 250 (July 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីរព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

President’s Messsage

# ជាភ័ព្វសំណាងណាស់ដែលខ្ញុំបានជួបអ្នក

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូកូសេកៃ



## ធ្វើតាមតែព្រហ្មលិខិតកំណត់មកដោយស្មោះត្រង់បានបទ

ខ្ញុំគន់មើលទៅព្រះច័ន្ទនៃរដូវផ្ការជាមួយនឹងភរិយារបស់ខ្ញុំដែលបានមកលេងនឹងខ្ញុំនៅយប់នេះ (ករី ម៉ូរី ស៊ីមីអ្វូ) — កំណាព្យហៃគឺនេះហាក់ដូចជាបង្ហាញពីមនោសញ្ចេតនាទៅលើសោភ័ណភាពនិងភាពសោកសង្រេងនៃព្រះច័ន្ទនៅពេលដែលកវីទទួលស្វាគមន៍ភរិយាដែលបានចែកស្ថានទៅហើយរួចហើយសម្លឹងមើលទៅលោកខែជាមួយគ្នានៅល្ងាចថ្ងៃដំបូងនៃបុណ្យផ្ទុំបិណ្ឌ។យើងឃើញដូចជាកវីកំពុងតែនិយា យទៅកាន់គូស្នេហាដែលចាកចេញពីគាត់ទៅហើយថា "បងកំពុងរស់នៅតាមរបៀបដែលអូនអាចមានមោទនភាពដូច្នេះសូមអូនជឿជាក់ហើយកុំបារម្ភ" ។

ទោះបីជាយើងមិនបានចងភ្ជាប់ដោយចំណងដ៏ជ្រាលជ្រៅដូចចំណងរបស់គូស្វាមីភរិយាក៏ដោយក៏គ្មាននរណាម្នាក់ក្នុងចំណោ មយើងទាំងឡាយអាចរស់នៅតែម្នាក់ឯងទាំងស្រុងបានដែរ។ដូចដែលអក្សរខាន់ជីចិនបង្ហាញពាក្យ "មនុស្ស" ស្រាប់ហើយថា យើងគ្រប់គ្នារស់នៅ"ក្នុងចំណោមមនុស្សដទៃទៀត" ហើយជីវិតរបស់យើងត្រូវបានត្បាញផ្គុំបចូលគ្នាដោយការប្រមូលផ្តុំនៃជំនួបជាមួយមនុស្សនិងអ្វីៗផ្សេងៗ។ ដូចដែលស្ថាបនិកកៃសូសាម៉ារបស់យើងបានបញ្ជាក់យ៉ាងច្បាស់ហើយថា "ជីវិតគឺជំនួប"។ទោះជាយ៉ាងណាក៏ដោយក្នុងចំណោមជំនួបទាំងឡាយ ក៏មានការជួបជាមួយនឹងអ្នកដែលបង្កឱ្យយើងមានទុក្ខវេទនា ឬមនុស្សដែលនាំឱ្យយើងមានការអាក់អន់ស្រពន់ចិត្ត និងការស្អប់ខ្ពើមមិនតិចផងដែរ។

នៅវេលាបែបនេះប្រសិនបើអ្នកគិតផ្តាសដូចជាថា"ខ្ញុំមិនត្រូវធាតុនឹងអ្នកនោះទេ" ហើយអ្នកមិនចង់ឃើញស្រមោលពួកគេឡើយ។ តែចំណែកខ្ញុំព្រះករុណាអាត្មាភាពវិញមិនដឹងជាយ៉ាងម៉េចរហូតមកដល់ពេលនេះតែងតែគិតថា ឱអ្នកនេះមានអ្វីដែលខ្ញុំគ្មានទេតើគួរឱ្យចាប់អារម្មណ៍មែន ឬក៏ថា ឱនៅលើលោកនេះមានមនុស្សគិតដូច្នេះដែរហ្ន! ហើយខ្ញុំព្រះករុណាអាត្មាភាពក៏ទទួលយកមិនបដិសេធគេឡើយ។

ដូចពាក្យចាស់បុរាណពោលថា "សូម្បីតែការជួបគ្នាដោយចៃដន្យក៏ជានិស្ស័យបន្តភ្ជាប់ពីជាតិមុនដែរ" ហើយនៅក្នុងព្រះពុទ្ធសាសនា ក៏មានពាក្យមួយឃ្លាថា "ការជួបគ្នាផ្ទាល់និងការអង្គុយជិតគ្នាសុទ្ធតែជានិស្ស័យពីជាតិមុនចំនួន ៥០០ជាតិ"។ ដោយសារសូម្បីតែមនុស្សដែលអ្នកជួបដោយចៃដន្យនៅតាមផ្លូវក៏ត្រូវបានគេជឿថាជានិស្ស័យដែលបានភ្ជាប់ដោយទំនាក់ទំនងកម្មយ៉ាងជ្រៅពីជាតិមុនដែរ ដូច្នេះ ការវិនិច្ឆ័យទៅលើ

ការជួបគ្នាថាល្អ ឬអាក្រក់ដោយផ្អែកទៅលើកាលៈទេសៈឬអារម្មណ៍ផ្ទាល់ខ្លួនគឺជាការគួរឱ្យសោកស្តាយពន់ពេកណាស់។

កវីថានីកាវ៉ា ស៊ុនតារ៉ូ បាននិយាយថា "ដោយសារគុណបុណ្យដែលបានជួបនឹងមនុស្សផ្សេងទៀត ទើបខ្ញុំអាចជួបខ្លួនឯងបាន"។ តាមរយៈការជួបជាមួយនឹងអ្នកដទៃ យើងចាប់ផ្តើមដឹងអំពីខ្លួនយើង ដែលយើងមិនបានដឹង ឬ យើងអាចរៀនអំពីទស្សនៈរបស់អ្នកដែលមិនយល់ស្របនឹងគំនិតយើង ដោយយើងអាចយកមកប្រើជាថ្នាំសំលៀងសម្រាប់ដុសខាត់កែលម្អខ្លួនយើងបាន។ គេនិយាយថា ដើម្បីកែលម្អអត្តចរិតនិងបុគ្គលិកលក្ខណៈ ហើយនិងធាតុជាមនុស្សរបស់ខ្លួនគេត្រូវមានចំនួនមនុស្ស ដែលយល់ស្រប និងមិនយល់ស្របនឹងគំនិតរបស់ខ្លួនស្មើភាគគ្នា។ក្នុងន័យនេះខ្ញុំព្រះករុណាអាត្មាភាពជឿថាការទទួលយកនិស្ស័យជាមួយនឹងមនុស្សពីព្រហ្មលិខិតដោយស្មោះត្រង់បានបទនៅពេលដែលមានឱកាសធ្វើឱ្យជីវិតរបស់មនុស្សម្នាក់កាន់តែសម្បូរបែប។

## ភ្ជាប់និស្ស័យជាមួយអ្នកដែលបានទទួលមរណភាពទៅហើយជាថ្មីម្តងទៀត

ទោះជាយ៉ាងណាក៏ដោយការទទួលយករឿងមិនល្អ ឬមនុស្សដែលយើងមិនចូលចិត្តដោយស្មោះត្រង់មិនមានការរារែកគឺជាការលំបាកពន់ពេកណាស់។ យ៉ាងណាក៏ដោយ ភ័ព្វល្អ ដោយសារគុណបុណ្យព្រះពុទ្ធយើងអាចជួបជាមួយនឹងមនុស្ស និងអ្វីៗនានាដោយស្មោះត្រង់បានបទបាន។ នៅក្នុងសមាគមរបស់យើង នៅពេលដែលយើងជួបមនុស្សឬស្ថានភាពដែលមិនមានអំណោយផលចំពោះយើង យើងត្រូវតែធ្វើស្វ័យត្រិះរិះឆ្លុះបញ្ចាំងថា"តើព្រះពុទ្ធកំពុងតែព្យាយាមបង្រៀនអ្វីដល់យើងនៅទីនេះ?" ហើយប្រើប្រាស់ឱកាសនេះដើម្បីពិនិត្យពិច័យដោយស្ងប់ស្ងាត់ថាតើហេតុអ្វីបានជាយើងយល់ឃើញថាវាមិនត្រូវនឹងកាលៈទេសៈរបស់យើងនិងតើអ្វីទៅដែលយើងត្រូវធ្វើឥឡូវនេះ។ ទម្លាប់នៃការតម្រូតចិត្តរបស់យើងជាមួយនឹងព្រះទ័យរបស់ព្រះពុទ្ធនេះធ្វើឱ្យយើងទៅជាស្មោះត្រង់បានបទបាន។

នៅពេលដែលយើងពិចារណាឱ្យកាន់តែជ្រៅបន្តិចទៀតទៅជាពិសេសជំនួបជាមួយនឹងមនុស្សគឺជាលទ្ធផលនៃការបន្តគ្នាជាប់ៗ (ស៊េរី) នៃហេតុផលនិងនិស្ស័យឬលក្ខណ្ឌផ្សេងៗដែលបង្កឱ្យមានព្រឹត្តិការណ៍អាថ៌កំបាំងកើតមានឡើង ។ ប្រសិនបើអ្នករកមើលពាក្យ «និស្ស័យ» នៅក្នុងវចនានុក្រមជប៉ុនអ្នកនឹងឃើញន័យថា «កម្លាំងអាថ៌កំបាំងមួយដែលហួសពីការគ្រប់គ្រងរបស់មនុស្ស ដែលភ្ជាប់មនុស្សនិងមនុស្ស» ដូច្នេះគេអាចនិយាយបានថា យើងបានជួបមនុស្សម្នាក់ៗដោយសារតែយើងត្រូវតែជួប។ បើគិតដល់ចំណុចនេះ យើងនឹងអាចនិយាយដោយស្មោះត្រង់ទៅកាន់មនុស្សគ្រប់គ្នាដែលយើងជួប មិនមែនត្រឹមតែប្តីឬប្រពន្ធ ឪពុកម្តាយ កូនៗ និងបងប្អូនរបស់យើងទេថា «ជាភ័ព្វសំណាងណាស់ដែលខ្ញុំបានជួបអ្នក» ហើយខ្ញុំព្រះករុណាអាត្មាភាពជឿថាមនុស្សគ្រប់គ្នានឹងចុះសម្រុងគ្នាហើយញញឹមដាក់គ្នាទៅវិញទៅមក។នេះគឺជាការរស់ស្របតាមគោលការណ៍នៃនិស្ស័យឬការភ្ជាប់ទំនាក់ទំនងរវាងគ្នានិងគ្នា ដែលបង្រៀនយើងថាអ្វីៗទាំងអស់សុទ្ធតែមានទំនាក់ទំនងជាមួយគ្នា។

នៅពេលដែលយើងខិតជិតដល់ឱកាសបុណ្យអូបុនដែលដូចជាបុណ្យផ្ចុំបិណ្ឌខ្មែរ យើងៗនឹងអាចភ្ជាប់ទំនាក់ទំនងជាមួយដូនតា,បុព្វបុរសនិងសមាជិកគ្រួសាររបស់យើងដែលបានចែកស្ថានទៅហើយជាថ្មីម្តងទៀត។ នៅពេលដែលយើងរំលឹកពីអតីតកាលយើងប្រាកដជានឹងធ្វើឱ្យមនោសញ្ចេតនាស្រឡាញ់ និងការដឹងគុណរបស់យើងឡើងកាន់តែជ្រាលជ្រៅ ដោយគិតថា "ជាភ័ព្វសំណាងណាស់ដែលខ្ញុំបានជួបអ្នក"។ ក្នុងពេលជាមួយគ្នានេះដែរ នៅពេលដែលយើងគិតពីតម្លៃនៃការអាចរស់រានមានជីវិត ពាក្យសច្ចារបស់យើងនឹងបន្លឺឡើងកាន់តែជ្រាលជ្រៅជាងពេលណាៗទាំងអស់នៅពេលដែលយើងសូត្រធម៌រំលឹកវិញ្ញាណក្ខន្ធនិងការឧទ្ទិសកុសលដើម្បីសុខុមាលភាពនៃវិញ្ញាណខន្ធក៏ដូចជាការរំពឹងទៅលើព្រះរតនៈត្រៃយើងនឹងបន្តការតាំងចិត្តរបស់យើងក្នុងការរស់នៅដោយរបៀបមួយដែលមិននាំមកនូវភាពអាម៉ាស់ដល់អ្នកដែលបានចែកស្ថានទៅហើយនោះទេ។



កាសែត កូសេ លេខខែ៧ឆ្នាំ២០២៦

# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




| Information about local Dharma centers | facebook | X |
|---|---|---|

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp